ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូង**
**ខេត្តបន្ទាយមានជ័យ**

**តុលាការរដ្ឋប្បវេណី**
សាលក្រមរដ្ឋប្បវេណីលេខ: ១៥ -ក-/២២១
ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣

រឿងក្តី: បណ្តឹងទាមទារប្រាក់
សំណុំរឿងរដ្ឋប្បវេណីលេខ: ១៥៥
ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣

## សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលសវនាការទី៣ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ ។

### ចៅក្រមជំនុំជម្រះ

ឯកឧត្តម [redacted] ប្រធានសាលាដំបូង

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូង

**ដើមចោទ:**

-ឈ្មោះ [redacted] ខាន់ ភេទស្រី អាយុ ៨៩ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋាននៅ [redacted] ។

-អ្នកតំណាងដោយអាណត្តិ: លោកមេធាវី [redacted] អត្តលេខ 2715T មានអាសយដ្ឋាន [redacted] ។

**ចុងចម្លើយ:**

-ឈ្មោះ [redacted] ចាន់រិត ភេទស្រី អាយុ៨២ឆ្នាំ និងឈ្មោះ [redacted] សុភា ភេទប្រុស អាយុ ៨៨ឆ្នាំ អាសយដ្ឋាននៅភូមិត្នោត [redacted] ។

**អង្គហេតុ និងចំណុចវិវាទ**

១.ខ្លឹមសារនៃសាលក្រមដែលសហដើមចោទទាមទារឲ្យតុលាការចេញ:

១.១.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ចាន់រិត និងឈ្មោះ [redacted] សុភា សងប្រាក់ដើម ចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត ឱ្យមកដើមចោទ ឈ្មោះ [redacted] ខាន់ ។



Scanned with CamScanner

១.២.បង្គាប់ឱ្យសហចុងចម្លើយបង់ការប្រាក់ចំនួន ២% ក្នុងមួយខែ លើប្រាក់ដើមចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត គិតចាប់ពីថ្ងៃខនខានបង់រហូតដល់ដាក់ពាក្យបណ្តឹងមកតុលាការ ឱ្យមកដើមចោទឈ្មោះ [redacted] ខាន់ ។

១.៣.ឱ្យអនុវត្តបណ្តោះអាសន្នលើចំណុចទី១ ទី២ ខាងលើ ។

១.៤.បង្គាប់ឱ្យសហចុងចម្លើយសងសំណងជំងឺចិត្តនិងការខាតបង់ពេលវេលាគិតជាប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ឱ្យទៅដើមចោទឈ្មោះ [redacted] ខាន់ ។

១.៥.ឱ្យសហចុងចម្លើយទទួលបន្ទុកលើប្រាក់ពន្ធនិងប្រាក់ប្រដាប់ក្តីផ្សេងៗ ។

<u>២.ដំណើររឿងក្តី និង ចំណុចវិវាទ:</u>

**២.១.ការសង្ខេបអំពីរឿងក្តី:**

-ដើមចោទទាមទារឱ្យសហចុងចម្លើយបង់ប្រាក់ចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត និងប្រាក់ ២% ក្នុង១ខែ នៃប្រាក់ចំនួន ១.២៦១.៥០០ ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាតបាត គិតចាប់ពីថ្ងៃខនខានថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃសងរួច ដោយមូលហេតុ ចាប់ពីអំឡុងឆ្នាំ២០១២ ដល់ឆ្នាំ ២០២១ សហចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទជាបន្តបន្ទាប់ និងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០២២ សហចុងចម្លើយទទួលស្គាល់ចំណុលសរុបនៅជំពាក់ប្រាក់ដើមចំនួន១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត ដោយបានចុះកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ បានកំណត់អត្រាការប្រាក់ចំនួន ២ % ក្នុងមួយខែ ។ ប៉ុន្តែចាប់ពីថ្ងៃចុះកិច្ចសន្យាខ្ចីប្រាក់នេះមក សហចុងចម្លើយបានខកខានបង់ការប្រាក់រហូតមក ។

**២.២.ចំណុចវិវាទ:** *តើការទាមទាររបស់ដើមចោទត្រឹមត្រូវតាមច្បាប់ និងមានភស្តុតាងបញ្ជាក់ដែរ ឬ ទេ?*

**២.៣.ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ:**

-**ការអះអាងរបស់ដើមចោទ:** ដើមចោទសូមរក្សាទុកនូវខ្លឹមសារក្នុងពាក្យបណ្តឹង ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ និងសេចក្តីថ្លែងការណ៍ដែល បានធ្វើនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ទុកជាបានការដដែល និងសូមបញ្ជាក់ថា ដើមចោទបានដាក់ពាក្យបណ្តឹងប្តឹងសហចុងចម្លើយមកសាលាដំបូងខេត្តបន្ទាយមានជ័យដែលមានខ្លឹមសារក្នុងកម្មវត្ថុគឺសុំឲ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារ:

១.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ចាន់រិត និងឈ្មោះ [redacted] សុភា សងប្រាក់ដើមចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត ឱ្យមកដើមចោទឈ្មោះ [redacted] ខាន់ ។



Scanned with CamScanner

២.បង្គាប់ឱ្យសហចុងចម្លើយបង់ការប្រាក់ចំនួន ២% ក្នុងមួយខែ លើប្រាក់ដើមចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត គិតចាប់ពីថ្ងៃខានខានបង់ រហូតដល់ដាក់ពាក្យបណ្តឹងមកតុលាការ ឱ្យមកដើមចោទឈ្មោះ [redacted] ខាន់ ។

៣.ឱ្យអនុវត្តបណ្តោះអាសន្នលើចំណុចទី១ ទី២ ខាងលើ ។

៤.បង្គាប់ឱ្យសហចុងចម្លើយសងសំណងជំងឺចិត្ត និងការខាតបង់ពេលវេលាគិតជាប្រាក់ចំនួន ៥០.០០០.០០០ (សែសិបលាន) រៀល ឱ្យទៅដើមចោទឈ្មោះ [redacted] ខាន់ ។

៥.ឱ្យសហចុងចម្លើយទទួលបន្ទុកលើប្រាក់ពន្ធនិងប្រាក់ប្រដាប់ក្តីផ្សេងៗ ។

សាលាដំបូងខេត្តបន្ទាយមានជ័យ បានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដោយកំណត់បានចំណុចវិវាទថា៖ *តើការទាមទាររបស់ដើមចោទត្រឹមត្រូវតាមច្បាប់ និងមាន ភស្តុតាងបញ្ជាក់ដែរឬទេ?* ក្នុងនេះដែរការទាមទារ និងភស្តុតាងក្នុងសំណុំរឿងនេះ គឺដើមចោទសូមធ្វើការបញ្ជាក់ជូនពាក់ព័ន្ធទៅ និងចំណុចវិវាទដូចតទៅ៖ អំពីអង្គហេតុកាលពីអំឡុងឆ្នាំ២០១២ និងឆ្នាំ២០១៣ សហចុងចម្លើយឈ្មោះ [redacted] ចាន់រីត និងប្តីឈ្មោះ [redacted] សុភា បានមកខ្ចីចងការពីដើមចោទជាបន្តបន្ទាប់ និងបានសងបណ្តោះជាហូរហែរផងដែរ ហើយចំពោះការខ្ចីប្រាក់នេះ គឺសហចុងចម្លើយយល់ព្រមឡើងការប្រាក់ឱ្យមកដើមចោទចំនួន២% ក្នុងមួយខែលើប្រាក់ដើម ប៉ុន្តែការទូទាត់សងប្រាក់ដើម និងការប្រាក់គឺទូទាត់នៅចុងឆ្នាំនីមួយៗ ដែលសហចុងសម្លើយបានខ្ចី ។ ក្រោយពីសហចុងចម្លើយខ្ចីប្រាក់រួច ដើមចោទបានសរុបប្រាក់ដើមដែលសហចុងចម្លើយបានខ្ចី គឺនៅសល់ប្រាក់បាតចំនួន ៣៣០.០០០ (បីសែនបីម៉ឺន) បាត, ប្រាក់ដុល្លារចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក ដោយក្នុងនោះការប្រាក់នៅខ្វះចំនួន ៦៩.៣០០ (ប្រាំមួយម៉ឺនប្រាំបួនពាន់បីរយ ) បាត ។ ក្នុងឆ្នាំ២០១៤ សហចុងចម្លើយបានមកខ្ចីពីដើមចោទចំនួន ៤ លើបន្ថែមទៀត គឺនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៤ ថ្វីចំនួន៥០.០០០ (ប្រាំម៉ឺន)បាត នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ ខ្ចីចំនួន ១៥.៨៥០ (មួយម៉ឺនប្រាំពាន់ប្រាំបីរយសែសិប) បាត, នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ ខ្ចីចំនួន ២៥.០០០ (ពីរម៉ឺនប្រាំពាន់) បាត, និងខ្ចីនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤ ខ្ចីចំនួន ៥.០០០ (ប្រាំពាន់) បាត ។ នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០១៥ សហចុងចម្លើយបានយកការប្រាក់មកឡើងឱ្យដើមចោទ ប៉ុន្តែការឡើងការប្រាក់នេះគឺមិនបានគ្រប់ចំនួននោះទ ដោយនៅខ្វះការប្រាក់ចំនួន៩៨.៧៨០ (ប្រាំបួនម៉ឺនប្រាំបីពាន់ប្រាំពីររយប៉ែតសិប) បាត ហើយប្រាក់ដើមនៅជំពាក់ដដែល គឺចំនួន ៤៤៩.០០០ (បួនសែនបួនម៉ឺនប្រាំបួនពាន់) បាត, ប្រាក់ដុល្លារចំនួន ២.០០០ (ពីរពាន់) ដុល្លាអាមេរិក រហូតដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៥ សហចុងចម្លើយបានមកខ្ចីប្រាក់ពីដើមចោទបន្ថែមចំនួន ៥០.០០០ (ប្រាំម៉ឺន) បាត ។ នៅក្នុងឆ្នាំ ២០១៦ សហចុងចម្លើយបានយកការប្រាក់មកទូរទាត់បង់ឱ្យដើមចោទ ប៉ុន្តែការប្រាក់ដែលត្រូវបង់ គឺមិនបានបង់ឱ្យគ្រប់ចំនួននោះទេ ចំណែកប្រាក់ដើមក៏សហចុងចម្លើយមិនបានសងដែរ ហើយក្នុងឆ្នាំនេះដែរសហចុងចម្លើយបានមកខ្ចីប្រាក់ពីដើមចោទបន្ថែមទៀតជាបន្តបន្ទាប់រហូតប្រាក់ដើម



Scanned with CamScanner

សរុបកើនឡើងដល់ទៅចំនួន ៥៣៣.០០០ (ប្រាំសែនបីម៉ឺនបីពាន់) បាត ។ នៅក្នុងឆ្នាំ២០១៧ សហចុងចម្លើយក៏បានមកខ្ចូវទាត់ឡើងការប្រាក់ លើប្រាក់ដើមចំនួន ៥៣៣.០០០ (ប្រាំសែនបីម៉ឺនបីពាន់) បាត ឱ្យមកដើមចោទ ប៉ុន្តែការប្រាក់ដែលសហចុងចម្លើយត្រូវឡើង គឺនៅតែមិនគ្រប់ចំនួនដូចរាល់លើកន្លងមក ដោយនៅខ្វះជាបន្តបន្ទាប់ ដែលសរុបទាំងប្រាក់ដើម និងការប្រាក់ឡើងរហូតដល់ចំនួន ៧២៥.០០០ (ប្រាំពីរសែនពីរម៉ឺនប្រាំពាន់) បាត និងប្រាក់ដុល្លារចំនួន ២.០០០ (ពីរពាន់) ដុល្លារអាមេរិក គិតដល់ឆ្នាំ២០១៨ ។ នៅក្នុងឆ្នាំ២០១៩ ដើមចោទបានសរុបចំនួនទឹកប្រាក់ដែលសហចុងចម្លើយជំពាក់ទាំងប្រាក់ដើមនៅការប្រាក់កើនរហូតដល់ទៅចំនួន ១.០២៥.៥០០៦ (មួយលានពីរម៉ឺនប្រាំបួនពាន់ប្រាំរយប្រាំមួយ) បាត និងប្រាក់ដុល្លាចំនួន ២.០០០ (ពីរពាន់) ដុល្លាអាមេរិក បើទោះបីជាប្រាក់ដើមកាន់តែកើនឡើងក៏ដោយ ក៏សហចុងចម្លើយតែងតែមកសុំខ្ចីបន្ថែមបន្តបន្ទាប់ដដែល ។ ក្នុងឆ្នាំ២០១៩នេះដែរដោយសារតែជំងឺកូវីដ ១៩ ផ្ទុះឡើង ត្រូវបានផ្ទុះឡើងកាន់តែខ្លាំងនៅក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ សហចុងចម្លើយឈ្មោះ [redacted] ចាន់រិត និងប្ដីឈ្មោះ [redacted] សុភា បានខកខានក្នុងការបង់ការប្រាក់ និងសងប្រាក់ដើមឱ្យមកដើមចោទ ហើយមិនត្រឹមតែមិនបានបង់ការប្រាក់ដើមប៉ុណ្ណោះទេ នៅក្នុងឆ្នាំ២០២១ នេះដែរ សហចុងចម្លើយបានមកខ្ចីប្រាក់ពីដើមចោទបន្ថែមទៀតចំនួន ៧០០.០០០ (ប្រាំពីរសែន) បាត ដែលធ្វើឱ្យប្រាក់ដើមនិងការប្រាក់កាន់តែកើនឡើងទៅៗ ។ ចំពោះប្រាក់ដើមទាំងប្រាក់បាត ប្រាក់ដុល្លារ និងការប្រាក់ដែលសហចុងមិនបានសងមកដើមចោទ គឺសរុបទាំងអស់មានចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយបាត) ។ ពេលឃើញសហចុងចម្លើយគាត់កាន់តែជំពាក់ទៅៗ និងមិនមានប្រាក់សង ដើមចោទមានការមិនទុកចិត្ត ក៏បានសុំឱ្យសហចុងចម្លើយសងប្រាក់នេះ ប៉ុន្តែសហចុងចម្លើយគ្មានប្រាក់សងដដែល ។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ សហចុងចម្លើយបានយល់ព្រមធ្វើកិច្ចព្រមព្រៀងមួយដោយ សហចុងចម្លើយសុំលក់ដីស្រែចំនួន ៥ ហិកតា ដើម្បីយកប្រាក់មកសងដើមចោទ ហើយនៅថ្ងៃដែលនេះដែរ សហចុងចម្លើយឈ្មោះ [redacted] ចាន់រិត និងប្ដីឈ្មោះ [redacted] សុភា ក៏បានយល់ព្រមព្រៀងធ្វើកិច្ចសន្យាខ្ចីប្រាក់ថ្មីមួយ ដែលកិច្ចសន្យានេះ គឺជាកិច្ចសន្យាដែលសរុបនូវទឹកប្រាក់ទាំងអស់ ដែលសហចុងចម្លើយបានជំពាក់ដើមចោទ នាពេលកន្លងមក ហើយក្នុងកិច្ចសន្យានេះមានបញ្ជាក់ចំនួនទឹកប្រាក់ជំពាក់ និងការប្រាក់ត្រឹមត្រូវ ព្រោះកន្លងមកសហចុងចម្លើយខ្ចីប្រាក់ពីដើមចោទជាច្រើនលើក និងច្រើនដំណាក់កាលវាមានការពិបាកក្នុងការគិត ។ ចំពោះកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ដែលជាកិច្ចសន្យាបូកសរុបទឹកប្រាក់ជំពាក់ចុង ក្រោយនេះ គឺមានចុះលេខ: ២១៧៨/២២ ឃស ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២២ ចុះហត្ថលេខាបញ្ជាក់ដឹងឮត្រឹមត្រូវពីលោក ជា ទី ជាមេឃុំផងដែរ ។ ក្រោយពេលធ្វើកិច្ចសន្យាខ្ចីប្រាក់នេះហើយ រហូតមកដល់បច្ចុប្បន្នសហចុងចម្លើយនៅតែពុំព្រមសងប្រាក់ឱ្យមកដើមចោទដដែល ហើយដើមចោទក៏ធ្លាប់បានឱ្យអាជ្ញាធរមូលដ្ឋាន ឃុំជួយដោះស្រាយដែរ ប៉ុន្តែសហចុងចម្លើយពុំចូលខ្លួនទៅដោះស្រាយតាមការកោះអញ្ជើញរបស់អាជ្ញាធរឡើយ ។



Scanned with CamScanner

អំពីភស្តុតាង: ឯកសារបញ្ជីស្នាមចំនួន៦ច្បាប់ដែលមានស្នាមមេដៃរបស់សហចុងចម្លើយស្ថិតក្នុងពេលខ្ចីប្រាក់មួយលើកៗ និងកិច្ចព្រមព្រៀងចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ដែលមានស្នាមមេដៃសហចុងចម្លើយ ព្រមទាំងកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៤ ដែលធ្វើឡើងរវាងដើមចោទនិងសហចុង ចម្លើយដោយមានទទួលដឹងពីអាជ្ញាធរមូលដ្ឋាន គឺជាភស្តុតាងដែលអាចបញ្ជាក់ដែលអាចឱ្យដើមចោទធ្វើ បណ្តឹងប្តឹងទាមទារបាន ។ អំពីអង្គច្បាប់: ផ្អែកតាមបញ្ញត្តិមាត្រា៥៧៩, មាត្រា៥៨៣ កថាខណ្ឌទី៣ មាត្រា៥៨៤ កថាខណ្ឌទី៣, មាត្រា៥៩១ និងមាត្រា ៩០៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ គឺដើមចោទមានសិទ្ធិអាចប្តឹងទាមទារត្រឹមត្រូវតាមច្បាប់ ។

ការសន្និដ្ឋាន: ផ្អែកតាមអង្គហេតុ ភស្តុតាង និងអង្គច្បាប់ខាងលើអាចសន្និបានថាសហចុងចម្លើយ ពិតជាបានខ្ចីប្រាក់ពីដើមចោទប្រាកដមែន ហេតុនេះសូមឱ្យតុលាការធ្វើការពិនិត្យនិងសម្រេចតាមកម្មវត្ថុនៃពាក្យបណ្តឹង ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ របស់ដើមចោទឈ្មោះ [redacted] ខាន់ ដោយសុំឱ្យតុលាការចេញសាល ក្រមសម្រេចដែលមាននខ្លឹមសារ៖

១-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ចាន់រិត និងឈ្មោះ [redacted] សុភា សងប្រាក់ដើមចំនួន ១.២៦១.៥០០ បាត (មួយលានសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត ឱ្យមកដើមចោទឈ្មោះ ឡី ខាន់ ។

២-បង្គាប់ឱ្យសហចុងចម្លើយបង់ការប្រាក់ចំនួន ២% ក្នុងមួយខែ លើប្រាប់ដើមចំនួន ១.២៦១.៥០០ បាត (មួយលានសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត គិតចាប់ពីថ្ងៃខានខានបង់រហូតដល់ដាក់ពាក្យបណ្តឹងមកតុលាការឱ្យមកដើមចោទឈ្មោះ [redacted] ខាន់ ។

៣-ឱ្យអនុវត្តបណ្តោះអាសន្នលើចំណុចទី១ ទីទី២ ខាងលើ។

៤-បង្គាប់ឱ្យសហចុងចម្លើយសងសំណងជំងឺចិត្តនិងការខាតបង់ពេលវេលាគិតជាប្រាក់ចំនួន ៨០.០០០.០០០ (សែសិបលាន) រៀល ឱ្យទៅដើមចោទឈ្មោះ [redacted] ខាន់ ។

៥-ឱ្យសហចុងចម្លើយទទួលបន្ទុកលើប្រាក់ពន្ធនិងប្រាក់ប្រដាប់ក្តីផ្សេងៗ ។

## សំអាងហេតុ

**១.អំពីការអវត្តមានរបស់សហចុងចម្លើយ:**

-នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ សហចុងចម្លើយអវត្តមានដោយគ្មានមូលហេតុ ។ ផ្អែកតាមរបាយការណ៍ស្តីពីការបញ្ជូន ឃើញថា: សហចុងចម្លើយបានទទួលដំណឹងអំពីកាលបរិច្ឆេទនៃការធ្វើនីតិវិធីនីមួយៗ និងបានទទួលនូវសេចក្តីថ្លែងការណ៍របស់ដើមចោទ ដែលបានធ្វើឡើងនៅកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ត្រឹមត្រូវហើយ ។ ដូចនេះ យោងតាមមាត្រា ២០១ កថាខណ្ឌ២ និងមាត្រា ២០២ ចំណុច ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការចាត់ទុកថា: សហចុងចម្លើយឈ្មោះ [redacted] គន្ធា បានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុដែលដើមចោទបានលើកឡើង ហើយតុលាការអាចចេញសាលក្រមកំបាំងមុខសហចុងចម្លើយបាន ។



Scanned with CamScanner

**២.អំពីការទាមទារប្រាក់ដើមចំនួន ១.២៦១.៥០០ ដុល្លារអាមេរិកៈ**

២.១.ដើមចោទទាមទារឲ្យសហចម្លើយសងប្រាក់ដើមចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត ដោយអះអាងថា: ចាប់ពីអំឡុងឆ្នាំ២០១២ ដល់ឆ្នាំ២០២១ សហចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទជាបន្តបន្ទាប់និងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ សហចុងចម្លើយទទួលស្គាល់បំណុលសរុបនៅជំពាក់ប្រាក់ដើមចំនួន១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត ដោយបានចុះកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ បានកំណត់អត្រាការប្រាក់ចំនួន ២ % ក្នុងមួយខែ និងត្រូវសងប្រាក់ដើមទាំងអស់មកឱ្យដើមចោទវិញ នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ ។ ប៉ុន្តែចាប់ពីថ្ងៃចុះកិច្ចសន្យាខ្ចីប្រាក់នេះមក សហចុងចម្លើយបានខកខានបង់ការប្រាក់រហូតមក ។

២.២.ផ្អែកតាមការកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ឃើញថា ពិតជាមានអង្គហេតុនៃការខ្ចីប្រាក់ជាបន្តបន្ទាប់សរុបចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត ដែលសហចុងចម្លើយបានខ្ចីប្រាក់ពីដើមចោទចាប់តាំងពីឆ្នាំ២០១២ ដល់ឆ្នាំ២០២១ សរុបចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត ដោយចុងចម្លើយបានសងការប្រាក់ជាបណ្តើរ និងពុំបានសងរំលោះប្រាក់ដើមនោះទេ រហូតដល់ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ទើបសហចុងចម្លើយខកខានសងការប្រាក់មកឱ្យដើមចោទ ។

*__ការសន្និដ្ឋាន:__* សហចុងចម្លើយពិតជាបានខ្ចីប្រាក់ពីដើមចោទ ដូចមាននៅកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ដែលកិច្ចសន្យានេះធ្វើឡើងស្របតាមមាត្រា៥៧៨ និងមាត្រា៥៧៩ នៃក្រមរដ្ឋប្បវេណី ។ ការទាមទាររបស់ដើមចោទលើប្រាក់កម្ចីចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត មានភស្តុតាងបញ្ជាក់ចំពោះការទាមទារ ហើយកិច្ចសន្យាក៏ដល់កំណត់សងចាប់តាំងពីថ្ងៃ០៣ ខែមីនា ឆ្នាំ២០២៣ ដែលជាថ្ងៃបញ្ចប់កិច្ចសន្យា ។ ហេតុនេះ សហចុងចម្លើយមានកាតព្វកិច្ចសងប្រាក់មកឲ្យដើមចោទវិញតាមមាត្រា ៥៩១ នៃក្រមរដ្ឋប្បវេណី ។

**៣.អំពីការទាមទារការប្រាក់ៈ**

-ដើមចោទទាមទារឱ្យសហចុងចម្លើយសងការប្រាក់ក្នុងអត្រាការប្រាក់ ២% (ពីរ) ភាគរយក្នុងខែ ស្មើនឹង ១៨% (ដប់ប្រាំបីភាគ) លើប្រាក់ដើមចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត គិតចាប់ពីថ្ងៃខកខានថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទូទាត់ចប់សព្វគ្រប់ ។ ផ្អែកតាមប្រការ២ នៃកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ឃើញថា គូភាគីបានព្រមព្រៀងគ្នាជាមុននូវការកំណត់អត្រាការប្រាក់ចំនួន ២% (ពីរ) ភាគរយ ក្នុងខែ ស្មើនឹង ១៨% (ដប់ប្រាំបីភាគ) លើប្រាក់ដើមចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត ។ ប៉ុន្តែផ្អែកតាមប្រកាសលេខ ១២៨ កយ.ប្រក /១១



Scanned with CamScanner

ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត របស់ក្រសួងយុត្តិធម៌ ឃើញថា អត្រាការប្រាក់ដែលគូភាគីបានព្រមព្រៀងខាងលើនេះ មានចំនួនលើសពីការកំណត់របស់ច្បាប់ ។ ហេតុនេះ គប្បីបន្ថយមកត្រឹមកម្រិតចំនួន ១.៥% ក្នុងមួយខែ ឬ ស្មើនឹង ១៨% ក្នុងមួយឆ្នាំ ស្របតាមប្រកាសខាងលើ ។

-ការកំណត់រយៈពេលដែលត្រូវបង់ការប្រាក់: ការប្រាក់ត្រូវគិតក្នុងអំឡុងពេលនៃកិច្ចសន្យា ស្របតាមមាត្រា៥៨៣ ចំណុច១ នៃក្រមរដ្ឋប្បវេណី ។ តាមការអះអាងរបស់គូភាគី ឃើញថា សហចុងចម្លើយបានខកខានបង់ការប្រាក់ចាប់ពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ រហូតដល់បច្ចុប្បន្ន។ ប៉ុន្តែផ្អែកតាមប្រការ ២ នៃកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ឃើញថា កិច្ចសន្យានេះ ត្រូវបានបញ្ចប់នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ ។ ដូចនេះដើមចោទអាចទាមទារការប្រាក់បានចាប់ពីថ្ងៃខកខាន ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ ។ *ការទាមទារអត្រាការប្រាក់ និងរយៈពេលនៃការបង់ការប្រាក់លើសពីនេះមិនត្រឹមត្រូវឡើយ គប្បីច្រានចោលការទាមទារ ។*

**៤.អំពីការទាមទារបង់ប្រាក់សំណងជំងឺចិត្ត និងការខាតបង់ពេលវេលា:**

-ដើមចោទឱ្យសហចុងចម្លើយសងសំណងជំងឺចិត្ត និងការខាតបង់ពេលវេលាគិតជាប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល ។ តុលាការយល់ឃើញថា ការទាមទារសំណងជំងឺចិត្ត និងការខាតបង់ពេលវេលា គឺជាផ្នែកមួយនៃសំណងការខូចខាតចំពោះការយឺតយ៉ាវដែលមានចែងនៅក្នុងមាត្រា ៣៩៨ មាត្រា ៣៩៩ និងមាត្រា ៤០៣ នៃក្រមរដ្ឋប្បវេណី ។ ចំពោះការទាមទារសំណងជំងឺចិត្ត និងការខាតបង់ពេលវេលាជាប្រាក់ ៤០.០០០.០០០ (សែសិបលាន) រៀល តុលាការឃើញថា មានចំនួនច្រើន ដែលគប្បីតុលាការសម្រេចក្នុងចំនួនមួយសមរម្យ ។

**៥.ស្តីពីបន្ទុកនៃប្រាក់ប្រដាប់ក្តី:**

-គប្បីឲ្យសហចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី តាមការទាមទាររបស់ដើមចោទតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**៦.ស្តីពីការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន:**

-ការទាមទារសាលក្រមអាចអនុវត្តជាបណ្តោះអាសន្នបាន មានលក្ខណៈត្រឹមត្រូវតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយហេតុថា ការទាមទាររបស់ដើមចោទ គឺជាការទាមទារប្រាក់ដែលជាការទាមទារសិទ្ធិលើទ្រព្យសម្បត្តិ ហើយដើមចោទមានកីភស្តុតាងច្បាស់លាស់បញ្ជាក់ចំពោះការទាមទារ ។ម្យ៉ាងវិញទៀត ការប្រកាសសាលក្រមឱ្យអនុវត្តជាបណ្តោះអាសន្ន ដើម្បីជៀសវាងការខូចខាតផលប្រយោជន៍របស់ដើមចោទក្នុងការដែលអូសបន្លាយនីតិវិធីបន្តទៀតដែលមិនសមហេតុផល ។ ហេតុនេះ គប្បីតុលាការប្រកាសឱ្យអនុវត្តបណ្តោះអាសន្នបាន ។



Scanned with CamScanner

# <u>សេចក្តីសម្រេចបញ្ចប់</u>

១/-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ចាន់រិត និងឈ្មោះ [redacted] សុភា បង់ប្រាក់ឱ្យទៅដើមចោទ ចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត ។

២/-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ចាន់រិត និងឈ្មោះ [redacted] សុភា បង់ប្រាក់ការប្រាក់ចំនួន ១,៥% ក្នុងមួយខែ ឬ ស្មើនឹង ១៨% ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ១.២៦១.៥០០ (មួយលានពីរសែនប្រាំមួយម៉ឺនមួយពាន់ប្រាំរយ) បាត គិតចាប់ពីថ្ងៃខនខានថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ ។ ការទាមទារលើសពីនេះច្រានចោល។

៣/-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ចាន់រិត និងឈ្មោះ [redacted] សុភា បង់ប្រាក់សំណងជំងឺចិត្ត និងការខាតបង់ពេលវេលា (ប្រាក់សំណងការខូចខាតចំពោះការយឺតយ៉ាវ) ឱ្យទៅដើមចោទចំនួន ២.០០០.០០០ (ពីរលាន) រៀល ។ ការទាមទារលើសពីនេះច្រានចោល ។

៤/-បង្គាប់ឱ្យសហចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី ។

៥/-សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន ។

*សាលក្រមនេះ ត្រូវបានទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣ ចំពោះមុខដើមចោទ និងកំបាំងមុខសហចុងចម្លើយ ។*

*អំឡុងពេលដែលសហចុងចម្លើយអាចប្តឹងទាស់បានត្រូវកំណត់ ៤ (បួន) សប្តាហ៍ គិតចាប់ពីថ្ងៃបានធ្វើការបញ្ជូនតាមការបិទប្រកាសជាសាធារណៈ ។ គូភាគីមានសិទ្ធិធ្វើបណ្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។*

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted]

---

*បានចម្លងត្រឹមត្រូវតាមច្បាប់ដើម*

*ថ្ងៃអង្គារ ១១រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពស ២៥៦៧*

*បន្ទាយមានជ័យ, ថ្ងៃទី១០ ខែតុលា ឆ្នាំ២០២៣*

**ក្រឡាបញ្ជី**

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

[redacted]

[redacted]



Scanned with CamScanner